# កម្មវិធីផ្តល់ជំនួយថវិកាខ្នាតតូច សម្រាប់ការងារនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៦

## អំពីគម្រោងសូជី

គម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ("សូជី") របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ធ្វើការងារជាមួយសហគមន៍ស្ត្រីស្រលាញ់ស្ត្រី បុរសស្រលាញ់បុរស អ្នកស្រលាញ់ទាំងពីរភេទ អ្នកប្តូរភេទ អន្តរភេទ និង ភេទផ្សេងទៀត (*យៀ*) ("LGBTIQ") នៅកម្ពុជា។ គោលបំណង និងសកម្មភាពសំខាន់របស់គម្រោង សូជី រួមមានការផ្តល់អំណាចដល់បណ្តាញអ្នកស្រលាញ់ភេទដូចគ្នា ការសិក្សាស្រាវជ្រាវករណីរំលោភបំពានសិទ្ធិមនុស្សលើសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា និងការតស៊ូមតិ ដើម្បីសម្របសម្រួលអោយមានការផ្លាស់ប្តូរគោលនយោបាយ និងច្បាប់ដែលពាក់ព័ន្ធនឹង សូជី នៅក្នុងប្រទេសកម្ពុជា។ គម្រោង សូជី ធ្វើការងារទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាននៅទូទាំងប្រទេសកម្ពុជា។

## កម្មវិធីផ្តល់ថវិកាខ្នាតតូចសម្រាប់ការងារនិន្នាការភេទ និងអត្តសញ្ញាយេនឌ័រ

គម្រោង សូជី របស់ ម.ស.ម.ក ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងជំនួយថវិកាជូនដល់អង្គការ និងបណ្តាញដែលធ្វើការងារលើកកម្ពស់សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា ក្នុងគោលបំណង ដើម្បីបង្កើនសមត្ថភាពអង្គការ និងបណ្តាញលើកកម្ពស់ការយល់ដឹង និងរៀបចំព្រឹត្តិការណ៍តស៊ូមតិនានា និងដើម្បីរៀបចំយុទ្ធនាការ និងកិច្ចការងារដទៃផ្សេងទៀត។ នាពេលកន្លងមក គម្រោង សូជី របស់ ម.ស.ម.ក បានគាំទ្រព្រឹត្តិការណ៍នានាពាក់ព័ន្ធនឹងទិវាអន្តរជាតិប្រឆាំងនឹងការរើសអើងលើអ្នកស្រលាញ់ភេទដូចគ្នា មោទនភាពអ្នកស្រលាញ់ភេទដូចគ្នា និងទិវាសិទ្ធិមនុស្សអន្តរជាតិ ក៏ដូចជាសន្និសីទសារព័ត៌មាន និងសកម្មភាពផ្សេងៗទៀត ដែលមានគោលបំណងកសាងសមត្ថភាពដល់អង្គការដែលធ្វើការងារគាំទ្រលើអ្នកស្រលាញ់ភេទដូចគ្នា និងបណ្តាញអ្នកស្រលាញ់ភេទដូចគ្នា និងលើកកម្ពស់ការយល់ដឹងពីតម្រូវការនៃការគោរព និងការការពារសិទ្ធិរបស់អ្នកស្រលាញ់ភេទដូចគ្នា។[1] ម.ស.ម.ក អាចនឹងផ្តល់ជំនួយថវិការហូតដល់ទឹកប្រាក់ចំនួន ៧០០ដុល្លាអាមេរិកជាអតិបរិមា តាមរយៈកម្មវិធីជំនួយថវិកាខ្នាតតូចរបស់គម្រោង សូជី។ ហើយគម្រោងយើងខ្ញុំនឹងផ្តល់ថវិកានេះ ពី១ រហូតដល់៤លើក ក្នុង១ឆ្នាំ ក្នុងអំឡុងឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦។

## លក្ខខណ្ឌដែលអាចទទួលបានជំនួយថវិកា

[1] កម្មវិធីផ្តល់ជំនួយថវិកាខ្នាតតូចនេះ គឺធ្វើឡើងដើម្បីគាំទ្រដល់ការកម្ពស់ការយល់ដឹង និងការតស៊ូមតិ សកម្មភាពធ្វើយុទ្ធនាការនានា។ ប្រសិនបើលោកអ្នកប្រឈមនឹងហានិភ័យ ឬត្រូវការជំនួយសង្គ្រោះបន្ទាន់ (រួមទាំង ជំនួយផ្នែកច្បាប់) សូមលោកអ្នក ទាក់ទងមក ម.ស.ម.ក យើងខ្ញុំនឹងផ្តល់ជំនួយផ្នែកច្បាប់ក្រោមមូលនិធិផ្សេងទៀត។

លោកអ្នកអាចដាក់គម្រោងសំណើដែលអាចធ្វើឡើងជាភាសាខ្មែរ ឬជាភាសាអង់គ្លេស សរសេរដោយដៃក៏បាន។ គម្រោងសំណើនេះត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចខាងក្រោម ៖

១. ការពិពណ៌នាសង្ខេបពីប្រវត្តិរូបរបស់បេក្ខជន(បេក្ខជនចាំបាច់ត្រូវតែមកពីអង្គការ ឬបណ្តាញដែលធ្វើការងារផ្នែកអ្នកស្រលាញ់ភេទដូចគ្នា ឬសកម្មជនធ្វើការងារផ្នែកអ្នកស្រលាញ់ភេទដូចគ្នា)

២. ពិពណ៌នាសង្ខេបពី ព្រឹត្តិការណ៍ ឬសកម្មភាព ដែលតម្រូវអោយបេក្ខជននឹងត្រូវស្នើសុំជំនួយថវិកា

៣. ត្រូវបញ្ជាក់ពីរយៈពេលនៃសកម្មភាព ដែលជំនួយថវិកាត្រូវប្រើប្រាស់ និង

៤. ត្រូវចាំបាច់បញ្ជាក់លម្អិតពីការចំណាយថវិកា មិនអោយលើសពីចំនួនទឹកប្រាក់ ៧០០ ដុល្លាអាមេរិក។

បន្ទាប់ពីបញ្ចប់គម្រោង បេក្ខជនតម្រូវអោយ ផ្តល់ជូនរបាយការណ៍សង្ខេបនៃព្រឹត្តិការណ៍នានា ភ្ជាប់ជាមួយនឹងរូបថតនៃព្រឹត្តិការណ៍ទាំងនោះ ព្រមទាំងវិក័យបត្រចំណាយនានាមកកាន់ ម.ស.ម.ក៕[2]

**<u>ការដាក់ពាក្យស្នើសុំ</u>**

បេក្ខជនអាចផ្ញើពាក្យស្នើសុំមកលោក នួន ស៊ីដារ៉ា តាមរយៈអ៊ីម៉ែល ៖ sidara.nuon@cchrcambodia.org ឬផ្ញើផ្ទាល់មកកាន់ការិយាល័យរបស់ ម.ស.ម.ក តាមអាសយដ្ឋាន៖ ផ្ទះលេខ ៧៩៨ ផ្លូវ ៩៩ ប្រអប់សំបុត្រ ១៥០៦ សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកលោក នួន ស៊ីដារ៉ា តាមរយៈលេខទូរស័ព្ទ ៖ (+៨៥៥) ០៩៧៩ ៦៦៦ ៥៦៦។

[2] ម.ស.ម.ក សូមរក្សាសិទ្ធិ អោយអ្នកទទួលជំនួយថវិកាសងត្រឡប់នូវចំនួនទឹកប្រាក់ដែលទទួលនោះ ប្រសិនបើប្រាក់នេះត្រូវបានប្រើប្រាស់មិនត្រឹមត្រូវ ឬមានការពាក់ព័ន្ធនឹងអំពើពុករលួយ។